00705144

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 14 / 06 / 2011
ម៉ោង (Time/Heure): 11:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

លេខ/No: D20/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**Chambres Extraordinaires au sein des Tribunaux Cambodgiens**

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 003/07-09-2009-ECCC/OCIJ**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 003/07-09-2009-ECCC-OCIJ**

**សៀវភៅចុះបណ្ដឹងឧទ្ធរណ៍**
**Record of Appeals**
**Registre des appels**

ឆ្នាំពីរពាន់ដប់មួយ ខែមិថុនា ថ្ងៃទីដប់បី វេលាម៉ោងពីររសៀល

យើង ហម ហ៊ែល និង សោម រតនា ក្រឡាបញ្ជីនៃសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ បានទទួលពាក្យបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិលោក Andrew CAYLEY ប្ដឹងឧទ្ធរណ៍នឹងដីកាសម្រេចស្ដីពី "សំណើសុំពន្យារពេល និងសំណើសុំឱ្យ បំពេញកិច្ចស៊ើបសួរ ដាក់ដោយ សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿងលេខ ០០៣" ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១១ ដែលត្រូវបានជូនដំណឹងក្នុងថ្ងៃ ខែ ឆ្នាំ ដដែល។

**អ្នកប្ដឹង**
**Appellants**

**ក្រឡាបញ្ជី**
**Greffiers**

ហម ហ៊ែល

សោម_រតនា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៥១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

00705145

ឯកសារ: D 20/4

| ឯកសារបកប្រែ |
| --- |
| TRANSLATION/TRADUCTION |
| ថ្ងៃ ខែ ឆ្នាំ (Date): 13-Jun-2011, 08:27 |
| CMS/CFO: Uch Arun |

នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**<u>ព័ត៌មានពិស្តារនៃការដាក់ឯកសារ</u>**

| | | |
| --- | --- | --- |
| សំណុំរឿងលេខ | : | ០០៣/០៧-០៩-២០០៩-អវតក/កសចស |
| ដាក់ទៅ | : | សហចៅក្រមស៊ើបអង្កេត |
| ថ្ងៃដាក់ | : | ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សេចក្តីជូនដំណឹងពីការដាក់បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹង "ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំពន្យារពេល និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ពន្ធនឹងសំណុំរឿងលេខ ០០៣" អនុលោមតាមវិធាន ៧៤.២ និង ៧៥.១ នៃវិធានផ្ទៃក្នុង**

---

| <u>អ្នកដាក់ឯកសារ:</u> | <u>អ្នកទទួលឯកសារ:</u> | <u>ចម្លងជូន:</u> |
| --- | --- | --- |
| សហព្រះរាជអាជ្ញាអន្តរជាតិ: | ការិ.សហចៅក្រមស៊ើបអង្កេត: | សហព្រះរាជអាជ្ញាជាតិ: |
| លោក Andrew CAYLEY | ចៅក្រម យូ ប៊ុនឡេង | លោកស្រី ជា លាង |
| | ចៅក្រម Siegfried BLUNK | |

00705146

ឯកសារ: D20/4

*សំណុំរឿងលេខ: ០០៣/០៧-០៩-២០០៩-អវតក/កសចស*

១. អនុលោមតាមវិធាន ៧៤.២ និង ៧៥.១ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិ[1] សូមដាក់សេចក្តីជូនដំណឹងនេះ ដែលជំទាស់ទៅនឹង "ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំពន្យារពេល និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដែលបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងទៅនឹងសំណុំរឿងលេខ ០០៣" ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ ("ដីកាសម្រេច")[2] ។ ហេតុដូចនេះ អនុលោមតាមវិធាន ៧៥.៣ និង ៧៥.៤ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិ សូមជូនដំណឹងដល់ សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះថា ខ្លួននឹងដាក់សេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ជូនអង្គបុរេជំនុំជម្រះ ក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ ចាប់តាំងពីថ្ងៃចេញសេចក្តីសំរេចនេះ។ នៅក្នុងសេចក្តីសន្និដ្ឋានទាំងនេះ មានមូលហេតុខាងអង្គហេតុ និងអង្គច្បាប់សំរាប់ធ្វើជាមូលដ្ឋានក្នុងការប្តឹងឧទ្ធរណ៍ ដោយមានរាល់ឯកសារគាំទ្រទាំងអស់ជូនទៅជាមួយផង ។ ដើម្បីកុំឱ្យសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ក្លាយទៅជាឥតន័យ សហព្រះរាជអាជ្ញាអន្តរជាតិ យល់ឃើញថា ដីកាសម្រេចដែលកំពុងមានបញ្ហានេះ គួរបានផ្អាកជាដដែលសិនរហូតទាល់តែអង្គបុរេជំនុំជម្រះ ចេញដីកាបង្គាប់ណាមួយផ្សេងពីនេះនៅក្នុងពេលដែលកំពុងរង់ចាំការចេញសេចក្តីសំរេចស្ថាពររបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ ៕

ធ្វើនៅភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១

លោក Andrew CAYLEY

សហព្រះរាជអាជ្ញាអន្តរជាតិ

---

[1] សេចក្តីជូនដំណឹងពីការដាក់បណ្តឹងឧទ្ធរណ៍នេះ ត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ឯង ព្រោះថាសហព្រះរាជអាជ្ញាជាតិមានការខ្វែងយោបល់គ្នាលើចំណាត់ការមួយនេះ ។ ទោះបីជាសហព្រះរាជអាជ្ញាអន្តរជាតិ យល់ឃើញថា វាមិនមានការចាំបាច់ក្នុងការកត់ត្រាអំពីការខ្វែងយោបល់នេះ ដើម្បីឱ្យការដាក់ឯកសារមានសុពលភាពក៏ដោយ ក៏វាត្រូវបានកត់ត្រាទុកនៅក្នុងបញ្ជីខ្វែងយោបល់គ្នាមួយ ដែលបានរក្សាទុកដោយក្រឡាបញ្ជីរបស់សហព្រះរាជអាជ្ញា ដើម្បីធានាថា វាត្រូវទៅតាមដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលជាប្រធានបទនៃបណ្តឹងឧទ្ធរណ៍នេះ ។

[2] ឯកសារលេខ D20/3, លេខERN 00702797-00702802 ។